# អង្គការអ្នកត្រួសត្រាយនៃកម្ពុជា

# របាយការណ៍បូកសរុប
# លទ្ធផលការងារប្រចាំឆ្នាំ២០២២

ប្រភពមូលនិធិ:

# មាតិកា


១. អំពីអង្គការអ្នកត្រួសត្រាយនៃកម្ពុជា ........ 3

២. ពត៌មានគម្រោង ........ 6

២.១. ខេត្តសៀមរាប ........ 6

២.២. ខេត្តកំពង់ធំ ........ 7

៣. ពិពណ៌នាសង្ខេបពីការរីកចម្រើនរបស់គម្រោង ........ 7

៤. របាយការណ៍ហិរញ្ញវត្ថុ ........ 10

៥. បញ្ហាប្រឈម ........ 11

៦. ផែនការទិសដៅការងារបន្ត ........ 11

៧. ឧបសម្ព័ន្ធ៖ ........ 13

# ១. អំពីអង្គការអ្នកត្រួសត្រាយនៃកម្ពុជា

អង្គការអ្នកត្រួសត្រាយនៃកម្ពុជា (អ.អ.ក) ដែលមានឈ្មោះជាភាសាអង់គ្លេសគឺ Trailblazer Cambodia Organization (TCO) គឺជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមិនស្វែងរកប្រាក់ចំណេញ ដែលត្រូវបានបង្កើតឡើងដោយក្រុមអ្នកជំនាញខាងវិស័យកសិកម្ម និងអភិវឌ្ឍជនបទ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សង្គមដោយធ្វើការជាដៃគូរជាមួយ រាជរដ្ឋាភិបាលកម្ពុជា អង្គការសង្គមស៊ីវិល និងវិស័យឯកជននានា។ អ.អ.ក បានចុះបញ្ជីទទួលស្គាល់នៅក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៨ តាមរយៈលិខិតទទួលស្គាល់លេខៈ ១០០២/សជណ និងបានធ្វើបច្ចុប្បន្នភាពឡើងវិញ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ តាមរយៈលិខិតទទួលស្គាល់លេខៈ១៥៦៧/ប្រក។ បច្ចុប្បន្ននេះ អ.អ.ក មានស្នាក់ការកណ្ដាលនៅខេត្តសៀមរាប ហើយបាន និងកំពុងប្រតិបត្តិការនៅក្នុងទូទាំងខេត្តសៀមរាប និងមានការិយាល័យរងមួយទៀតនៅក្នុងខេត្តកំពង់ធំ។ ជាមួយនឹងបទពិសោធន៍យ៉ាងទូលំទូលាយជាងដប់ឆ្នាំ ក្នុងការអនុវត្តគម្រោងទាំងផ្នែកមនុស្សធម៌ និងការអភិវឌ្ឍន៍ អ.អ.ក បានទទួលជោគជ័យក្នុងការគ្រប់គ្រង និងអនុវត្តគម្រោងជាច្រើនទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិ គម្រោងកែលម្អជីវភាពរស់នៅ និងសន្តិសុខស្បៀង គម្រោងពាក់ព័ន្ធនឹងអនាម័យ ទឹកស្អាត គម្រោងអប់រំជាដើម ដែលត្រូវបានគាំទ្រថវិកា និងជំនួយបច្ចេកទេសដោយម្ចាស់ជំនួយអន្តរជាតិ និងដៃគូមួយចំនួនរួមមាន USAID, UNDP, EU/IFAD, AFD, WorldFish, ESB, APDRA, CIRAD, IRD, ADIC, EFF and Staving No More។

យើងមានផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ យ៉ាងជាក់លាក់ និងមានទស្សនវិស័យយ៉ាងទូលំទូលាយដូចខាងក្រោម៖

- **<u>ទស្សនវិស័យ</u>** ៖ អង្គការអ្នកត្រួសត្រាយនៃកម្ពុជា មានទស្សនៈវិស័យទូលំទូលាយគឺ "ចង់ឃើញគ្រួសារគោលដៅទាំងឡាយ រស់នៅប្រកបដោយភាពពេញបរិបូរណ៌"។
- **<u>បេសកកម្ម</u>** ៖ យើងមានបេសកកម្មចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ក្នុងតំបន់គោលដៅនៃ ប្រទេសកម្ពុជា និងចូលរួមកែលម្អគុណភាពជីវិតដល់គ្រួសារដែលរស់នៅទីនោះ។
- **<u>គោលដៅ</u>**

  អង្គការអ្នកត្រួសត្រាយនៃកម្ពុជា មានគោលដៅយុទ្ធសាស្ត្រសំខាន់ៗប្រាំគឺ៖
  - លើកកំពស់កំរិតជីវភាព និងសុវត្ថិភាពស្បៀងដល់គ្រួសារគោលដៅ
  - បង្កើនការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តភាព
  - លើកកំពស់សេវា និងមធ្យោបាយទឹកស្អាត និង អនាម័យ
  - បង្កើនការអប់រំនៅតំបន់គោលដៅ
  - កៀគរធនធានដើម្បីនិរន្តភាពស្ថាប័ន ក្នុងការចូលរួមបំពេញនូវតំរូវការរបស់សហគមន៍
- **<u>គុណតម្លៃ</u>**
  - ការប្តេជ្ញាចិត្តខ្ពស់
  - ភាពស្មោះត្រង់
  - ការទទួលខុសត្រូវ
  - ការគោរព

## អំពីក្រុមប្រឹក្សាភិបាលរបស់អង្គការ

| ឈ្មោះ | ឋានៈ និង ស្ថាប័ន | អាស័យដ្ឋាន |
|---|---|---|
| លោកស្រី ញាណ ភួងម៉ាលី | ប្រធានក្រុមប្រឹក្សាភិបាល | សៀមរាប |
| លោក សាន សារីដេត | សមាជិកក្រុមប្រឹក្សាភិបាល | សៀមរាប |
| លោក អឿ អ៊ីល | សមាជិកក្រុមប្រឹក្សាភិបាល | ភ្នំពេញ |
| លោក យូ ច័ន្ទប្រសិទ្ធ | សមាជិកក្រុមប្រឹក្សាភិបាល | ភ្នំពេញ |
| លោក សន សាមួន | សមាជិកក្រុមប្រឹក្សាភិបាល | ភ្នំពេញ |

## បុគ្គលិកលេខាធិការដ្ឋាន

| ល.រ | ឈ្មោះ | ភេទ | មុខងារ | អាស័យដ្ឋាន |
|---|---|---|---|---|
| 1 | ចេប ម៉ាលីបុប្ផា | ស្រី | នាយិកាប្រតិបត្តិ | សៀមរាប |
| 2 | សេង សុជាតា | ស្រី | ប្រធានរដ្ឋបាល និងហិរញ្ញវត្ថុ | សៀមរាប |
| 3 | ចាប ប៊ុនថន | ប្រុស | មន្រ្តីត្រួតពិនិត្យ និងវាយតម្លៃ | សៀមរាប |
| 4 | ពាង សុខា | ស្រី | គណនេយ្យ | សៀមរាប |
| 5 | ជា អន | ស្រី | បេឡាធិការនី | សៀមរាប |
| 6 | ថៃ ពិសី | ប្រុស | មន្ត្រីទំនាក់ទំនង | សៀមរាប |
| 7 | ចក់ វត្ថា | ប្រុស | អ្នកសម្របសម្រួលសហគមន៍ | កំពង់ធំ |
| 8 | សាមុត ពីរ៉ានេរ | ស្រី | មន្ត្រីស្រាវជ្រាវ និងសកម្មភាព | សៀមរាប |
| 9 | ប្រាញ ធារ៉ាំង | ស្រី | មន្ត្រីទីផ្សារ | សៀមរាប |
| 10 | ស៊ាង រ៉ា | ស្រី | ប្រធានក្រុមផលិត | សៀមរាប |
| 11 | ផេង ស្រីល័ក្ខ | ស្រី | ជំនួយការផលិតកម្ម | សៀមរាប |
| 13 | ថាត់ នាង | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 14 | នូ ចន្ទី | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 15 | ហាក់ ហ៊ុន | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 16 | វី ចន្ថា | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 17 | ក្រាក់ ផៃ | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 18 | ចាន់ រ៉ា | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 19 | ពៅ នាង | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 20 | វី ស្រីយុន | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 21 | ក្រាក់ សុភា | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 22 | អ៊ឹម ចិន្តា | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 23 | សុខ គារ៉ា | ប្រុស | ធ្វើសាប៊ូ | សៀមរាប |

| | | | | |
|---|---|---|---|---|
| 24 | ហ៊ុក គឹមលី | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 25 | ញ៉យ សូនី | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 26 | ទុយ រិន | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 27 | យង់ មី | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 28 | អ៊ឹម ណារិន | ប្រុស | ធ្វើសាប៊ូ | សៀមរាប |
| 29 | ឡាយ សេដា | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 30 | ទុំ សល្យ | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 31 | វ៉ាយ ស្រីមុំ | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 32 | ផាត និមល | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 33 | ឃួន កែវ | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 34 | ទ្វៀ ចាន់ម៉ៃ | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 35 | សុខ ស្រីម៉េង | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 36 | កុត ប្រិច | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 37 | កន ម៉ុន | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 38 | វង់ សៅម៉ៅ | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 39 | ប៉ាន សុភី | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 40 | ហ៊ឹង ស្រីហ៊ាក់ | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 41 | លឿម ផលលែន | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 42 | សំ បូរ៉ា | ប្រុស | ធ្វើសាប៊ូ | សៀមរាប |
| 43 | ហ៊ឹង ស្រីឃួច | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 44 | លឿម លាំ | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 45 | ប៊ុន ផាត | ប្រុស | អ្នកសម្របសម្រួលសហគមន៍ | សៀមរាប |
| 46 | តៅ ឡាយ | ប្រុស | អ្នកសម្របសម្រួលសហគមន៍ | សៀមរាប |

## វិស័យផ្តោតការយកចិត្តទុកដាក់

| គម្រោង | ទីកន្លែង | រយៈពេល | ដៃគូគម្រោង | ប្រភពថវិកា / ជំនួយ | ស្ថានភាព |
|---|---|---|---|---|---|
| គម្រោងកែច្នៃសាប៊ូ | ខេត្ត សៀមរាប | ១០ឆ្នាំ ២០១៤-២០២៤ | អ៊ី.អ៊ែស.បី | អ៊ី.អ៊ែស.បី | កំពុងដំណើរការ |

| | | | | | |
|---|---|---|---|---|---|
| គម្រោងអភិវឌ្ឍខ្សែច្រវ៉ាក់តម្លៃត្រី | ខេត្តសៀមរាប | ៣០ខែ ២០២០-២០២២ | អង្គការអាប់ជ្រា និងវិទ្យាស្ថានស្រាវជ្រាវស៊ីរ៉ាត | AFD | កំពុងដំណើការ |
| គម្រោង Aqua-CAM | ខេត្តសៀមរាប | ១៧ខែ ២០២១-២០២២ | អង្គការអាប់ជ្រា វិទ្យាស្ថានស្រាវជ្រាវស៊ីរ៉ាត និង អាយ.អ.ឌី | FSPI | បានបញ្ចប់ |

# ២. ពត៌មានគម្រោង

## ២.១. ខេត្តសៀមរាប

មាន៥គម្រោងដែលប្រភពថវិកាមកពីម្ចាស់ជំនួយ

**គម្រោងទី១**

| | |
|---|---|
| ឈ្មោះគម្រោង | ធនាគារសាប៊ូ |
| គោលបំណងរួម | ១. លើកកំពស់សេវា និងមធ្យោបាយអនាម័យស្អាត<br>២. កាត់បន្ថយផលប៉ះពាល់ទៅលើបរិស្ថាន<br>៣. និងលើកកម្ពស់សេដ្ឋកិច្ចស្ត្រីនៅក្នុងសហគមន៍ |
| តំបន់គោលដៅ | -ខេត្តៈ សៀមរាប |
| ក្រុមគោលដៅ | -ប្រជាពលរដ្ឋទូទៅដែលមានតម្រូវការប្រើប្រាស់សាប៊ូដើម្បីធ្វើអនាម័យប្រចាំថ្ងៃ |
| អ្នកទទួលផលផ្ទាល់ | អង្គការជាតិ អង្គការអន្តរជាតិ សាលារៀន និងសហគមន៍ |
| អ្នកទទួលផលប្រយោល | ៤៨,១៣៩ នាក់ |

❖ **គម្រោងទី២**

| | |
|---|---|
| ឈ្មោះគម្រោង | គម្រោងការអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃត្រី(DeFip) |
| គោលដៅរួម | ១. ពង្រឹង និងពង្រីកសក្តានុពលនៃការផលិតត្រីតាមលក្ខណៈកសិ-អេកូឡូស៊ី និងផលចំណេញ<br>២. លើកកម្ពស់ការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារជា យុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍជនបទ ប្រកបដោយនិរន្តរភាពនៅតំបន់ជុំវិញបឹងទន្លេសាប<br>៣.ពង្រឹងប្រព័ន្ធអេកូឡូស៊ី ដំណាំស្រូវ ទៅជាប្រព័ន្ធវារីវប្បកម្មស្រូវចម្រុះ និងផលិតកម្ម |

| | |
|---|---|
| តំបន់គោលដៅ | ខេត្តៈ សៀមរាប |
| ក្រុមគោលដៅ | កសិករចិញ្ចឹមត្រីនៅតាមស្រះភ្ជាប់នឹងវាលស្រែ |
| អ្នកទទួលផលផ្ទាល់ | ៣០ គ្រួសារ |
| អ្នកទទួលផលប្រយោល | ១៥០គ្រួសារ ស្មើ ៧៥០នាក់ |

❖ **គម្រោងទី៣**

| | |
|---|---|
| ឈ្មោះគម្រោង | គម្រោង Aqua-CAM |
| គោលបំណងរួម | ១.លើកកំពស់កម្រិតជីវភាព និងសុវត្ថិភាពស្បៀងដល់គ្រួសារគោលដៅ<br>២.បង្កើនការគ្រប់គ្រងធនធានមច្ឆាជាតិប្រកបដោយនិរន្តភាព និងប្រសិទ្ធភាពនៃប្រព័ន្ធផលិតកម្ម |
| តំបន់គោលដៅ | ខេត្តៈ សៀមរាប |
| ក្រុមគោលដៅ | កសិករចិញ្ចឹមត្រីនៅតាមស្រះភ្ជាប់នឹងវាលស្រែ |
| អ្នកទទួលផលផ្ទាល់ | ៣០ គ្រួសារ |
| អ្នកទទួលផលប្រយោល | ១៥០គ្រួសារ ស្មើ ៧៥០នាក់ |

## ២.២. ខេត្តកំពង់ធំ

**គម្រោងទី១**

| | |
|---|---|
| ឈ្មោះគម្រោង | គម្រោងការអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃត្រី (DeFip) |
| គោលបំណងរួម | ១.លើកកម្ពស់សុវត្ថិភាពស្បៀង និងអាហារូបត្ថម្ភសម្រាប់គ្រួសារកសិករនៅក្នុងតំបន់គោលដៅ<br>២.លើកកម្ពស់ជីវភាពរបស់ប្រជាកសិករតាមរយៈការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារបែបអេកូឡូស៊ីប្រកបដោយនិរន្តរភាពនៅតំបន់ជុំវិញបឹងទន្លេសាប |
| តំបន់គោលដៅ | • **ខេត្តកំពង់ធំ** (ស្រុកកំពង់ស្វាយ និងស្រុកសន្ទុក) |
| ក្រុមគោលដៅ | កសិករចិញ្ចឹមត្រីនៅតាមស្រះភ្ជាប់នឹងវាលស្រែ |
| អ្នកទទួលផលផ្ទាល់ | ១៥ គ្រួសារ |
| អ្នកទទួលផលប្រយោល | ៥០គ្រួសារ ស្មើ ៥៥០នាក់ |

# ៣. ពិពណ៌នាសង្ខេបពីការរីកចម្រើនរបស់គម្រោង

➢ **គម្រោងទី១**

អង្គការអ្នកគ្រួសត្រាយនៃកម្ពុជា ក៏បានអនុវត្តគម្រោងដែលអាក់ទងនឹងវិស័យបរិស្ថានផងដែរគឺមានឈ្មោះថា ធនាគារ សាប៊ូ ដែលសកម្មភាពនេះបានធ្វើការប្រមូលដុំសាប៊ូដែលបានប្រើប្រាស់រួចនៅតាមសណ្ឋាគារ ផ្ទះសំណាក់ ប៊ូទិក ជាដើម ដើម្បីធ្វើការកែច្នៃឡើងវិញក្នុងគោលបំណងដើម្បីចែកចាយទៅតាមសាលារៀន និងសហគមន៍ ធ្វើយ៉ាងណា ឱ្យតំបន់គោលដៅរបស់គម្រោងទទួលបានសេវាអនាម័យគ្រប់ៗគ្នា។

| **គម្រោង** | **លទ្ធផលរំពឹងទុកឆ្នាំ២០២២** |
|---|---|

| | |
|---|---|
| គម្រោងកែច្នៃសាប៊ូ Eco-Soap Banks | • សាប៊ូដែលគេប្រើប្រាស់រួចត្រូវបានប្រមូលយកមកកែច្នៃឡើងវិញ<br>• ស្ត្រី និងកុមារងាយរងគ្រោះនឹងទទួលបានសាប៊ូប្រើប្រាស់<br>• ក្រុមស្ត្រីមួយចំនួនទទួលបានការងារធ្វើ |

**លទ្ធផលសម្រេចបានឆ្នាំ ២០២២**

❖ ប្រភេទសាប៊ូដុំមានទំងន់:

- ១២៥ ក្រាម = ៤៦,៩២២ដុំ
- ១០០ ក្រាម = ៣៧១,៦៦៧ដុំ
- ៨០ ក្រាម = ២៦០ដុំ
- ៥០ ក្រាម = ២០,២៦០ដុំ

សរុប = ៤៣៩,១០៩ដុំ

❖ ប្រភេទសាប៊ូរូបមានទំងន់:

- ៥០ ក្រាម = ៥,៦០៧ដុំ
- ៤០ ក្រាម = ២៦៧,៦៥៤ដុំ
- ៣៥ ក្រាម = ២០០ដុំ
- ៣០ ក្រាម = ៥០ដុំ
- ២៥ ក្រាម = ១៨,៩១២ដុំ
- ២០ ក្រាម = ៧,៥០៧ដុំ
- ១៥ ក្រាម = ៣,០០០ដុំ
- ១០ ក្រាម = ២,៣៤៥ដុំ

សរុប = ៣០៥,២៧៥ដុំ

- បានចែកសាប៊ូទៅអង្គការដៃគូចំនួន៣២ ស្មើនឹងសាប៊ូចំនួន១៤៥,៧៩៧ ដុំ
- បានចែកសាប៊ូទៅសាលារៀនចំនួន១០ ស្មើនឹងសាប៊ូចំនួន១៦,៩០៥ ដុំ
- បានផ្តល់ជូននូវសាប៊ូលាងដៃទៅរដ្ឋបាលស្រុកក្នុងខេត្តសៀមរាប ចំនួន១០,០០០ ដុំ ដើម្បីរួមចំណែកក្នុងការទប់ស្កាត់ការរីករាលដាលឡើងវិញនៃជំងឺកូវីដ-១៩

➢ **គម្រោងទី២**

អង្គការអ្នកត្រួសត្រាយនៃកម្ពុជា បានសហការជាមួយនឹងវិទ្យាស្ថានជាតិបារាំង សម្រាប់ការស្រាវជ្រាវ និងការអភិវឌ្ឍន៍ និងអង្គការអាប់ជ្រា ដោយមានការគាំទ្រថវិកាពីកម្មវិធីមូលនិធិសាមគ្គីសម្រាប់ការអភិវឌ្ឍន៍ស៊ីវិល ដែលហៅកាត់ថា (FSPI) មានរយៈពេល១៧ខែ។ គម្រោងមានគោលបំណង លើកកំពស់កម្រិតជីវភាព និងសុវត្ថិភាពស្បៀងដល់គ្រួសារគោលដៅ តាមរយៈការបង្កើនការគ្រប់គ្រងវារីវប្បកម្ម តាមបែបក្សេត្របរិស្ថានប្រកបដោយនិរន្តភាព។ គម្រោងផ្តោតទៅលើសកម្មភាពស្រាវជ្រាវលើការចិញ្ចឹមត្រីក្នុងប្រព័ន្ធវាលស្រែរបស់ប្រជាកសិករនៅក្នុងខេត្តសៀមរាប

| គម្រោង | លទ្ធផលរំពឹងទុកឆ្នាំ២០២២ |
|---|---|
| គម្រោង Aqua-CAM | • បង្កើនប្រសិទ្ធភាពនៃប្រព័ន្ធផលិតកម្មឱ្យមាននិរន្តរភាព<br>• ធ្វើការវាយតម្លៃលើបញ្ហាសុខភាពត្រី និងសុវត្ថិភាពចំណីអាហារ |

| | |
|---|---|
| | • ការបណ្តុះបណ្តាលតាមរយៈការស្រាវជ្រាវ និងការអប់រំ |

| **លទ្ធផលសម្រេចបានឆ្នាំ ២០២២** |
|---|
| • បានធ្វើការសម្ភាសន៍ជាមួយនឹងកសិករចំនួន២៥០គ្រួសារ នៅក្នុងឃុំចំនួន១២ នៃស្រុកចំនួន៥ (ទ្រាំង ត្រាំកក់ ព្រៃកប្បាស អង្គរបុរី និងស្រុក សំរោង) នៃខេត្តតាកែវ អំពី ទស្សនៈ ឬ គោលគំនិតនៃការចិញ្ចឹមត្រីនៅក្នុងប្រព័ន្ធវាលស្រែ។<br>• បានសហការជាមួយនឹងគម្រោងអភិវឌ្ឍខ្សែច្រវ៉ាក់តម្លៃត្រីនៅកម្ពុជា ក្នុងការសាកល្បងអនុវត្តការចិញ្ចឹមត្រីនៅក្នុងប្រព័ន្ធវាលស្រែជាមួយ នឹងកសិករចំនួន៣០គ្រួសារនៅក្នុងស្រុកចំនួនបី។<br>• បានចូលរួមនៅក្នុងសិក្ខាសាលា ស្តីអំពីសរស្តម្ភទាំងបួន នៅក្នុងផ្នែកវារីវប្បកម្ម ជាមួយនឹងសកលវិទ្យាល័យភូមិន្ទ ចំការដូង វិទ្យាស្ថានស្រាវជ្រាវកសិកម្ម និងអង្គការដៃគូនានា។<br>• បានសហការជាមួយនឹងអង្គការដៃគូ ដើម្បីរៀបចំសិក្ខាសាលាបង្ហាញលទ្ធផលរបស់គម្រោង និងបញ្ចប់គម្រោងផងដែរ។ |

➢ **គម្រោងទី៣**

អង្គការអ្នកគ្រួសក្រោយនៃកម្ពុជា បានសហការជាមួយអង្គការអាប់ជ្រា ដោយមានការគាំទ្រថវិកាពី ទីភ្នាក់ងារអភិវឌ្ឍបារាំង ក្នុងការអនុវត្តន៍គម្រោងនេះ។ គម្រោងនេះ ត្រូវបានអនុវត្តដោយដៃគូនៅក្នុងប្រទេស៤ផ្សេងទៀតនៅទ្វីបអាហ្វ្រិក ដូចជាប្រទេស កុងហ្គោ ម៉ាដាកាស្កា កូដវ័រ និង កាម៉ារ៉ូន។ គម្រោងនេះ មានគោលបំណងក្នុងការលើកកម្ពស់ការចិញ្ចឹមត្រីតាមបែបកែ្សត្របរិស្ថាន ប្រកបដោយនិរន្តភាព។

| **គម្រោង** | **លទ្ធផលរំពឹងទុកឆ្នាំ២០២២** |
|---|---|
| អភិវឌ្ឍន៍ខ្សែរសង្វាក់តម្លៃត្រីនៅកម្ពុជា | • ដើម្បីលើកកម្ពស់ការចិញ្ចឹមត្រី ជាលក្ខណៈគ្រួសារបែបអេកូឡូស៊ីប្រកបដោយនិរន្តរភាពនៅតំបន់ជុំវិញបឹងទន្លេសាប។<br>• ប្រជាកសិករចូលរួមក្នុងការសាកល្បងនូវបច្ចេកទេសចិញ្ចឹមត្រីភ្ជាប់នឹងវាលស្រែ។ |

| **លទ្ធផលសម្រេចបានឆ្នាំ ២០២២** |
|---|
| • បានជ្រើសរើសកសិករថ្មីចំនួន ១៥នាក់បន្ថែមទៀត សរុបចំនួន៣០នាក់ (ក្រឡាញ់ ១៥នាក់ និង សូទ្រនិគមចំនួន ១៥នាក់<br>• បានរៀបចំកិច្ចប្រជុំចែករំលែក និងផ្ទៀងផ្ទាត់ទិន្នន័យនៃការប្រមូលផលជាមួយកសិករវគ្គមុនចំនួន ២ដង ដែលមានអ្នកចូលរួមសរុបចំនួន នាក់ ១៥នាក់ ក្នុងនោះមានស្រ្តីចំនួន ៥នាក់<br>• បានរៀបចំដំណើរទស្សនកិច្ចសិក្សាសម្រាប់កសិករពីក្រឡាញ់ មកសូទ្រនិគម ចំនួន១ដង និងនាំកសិករពីសូទ្រនិគម ទៅទស្សនកិច្ចនៅក្រឡាញ់ចំនួន ១ដង ដែលមានអ្នកចូលរួមសរុបចំនួន៣០នាក់ ក្នុងនោះមានស្រ្តីចំនួន ៥នាក់<br>• បានរៀបចំទទួលដំណើរទស្សនកិច្ចរបស់កសិករនៅកំពង់ធំ ចំនួន ២ដង ដើម្បីចែករំលែកចំណេះដឹង និងបទពិសោធន៍នៃការចិញ្ចឹមត្រីក្នុងប្រព័ន្ធវាលស្រែ<br>• បានរៀបចំទស្សនកិច្ចសិក្សា ទៅកសិដ្ឋានផលិតភ្ញាស់កូនត្រីពូជ នៅក្នុងខេត្តសៀមរាប ដើម្បីឲ្យកសិករនៅក្នុងគម្រោងបានសិក្សា និងស្គាល់ពីទីតាំងកន្លែងផលិតកូនត្រី ដែលនៅជិតគាត់។ |

- បានដឹកនាំទស្សនកិច្ចសិក្សាសម្រាប់កសិករទៅ ស្ថានីយ៍បង្កាត់ភ្ញាស់ កសិដ្ឋានភ្ញាស់ និងបន្សាំកូនត្រី មានអ្នកចូលរួម១៣នាក់ស្រី០៣នាក់
- បានរៀបចំវគ្គបណ្តុះបណ្តាលចំនួន ១៨វគ្គ ដល់កសិករដែលក្នុងកសិករម្នាក់ៗ ទទួលបានវគ្គបណ្តុះបណ្តាលចំនួន ០៤ មេរៀនមានដូចជា៖
  - ➢ មូលដ្ឋានគ្រឹះនៃការចិញ្ចឹមត្រី ការកត់ត្រាចំណូលចំណាយនៃការចិញ្ចឹមត្រី
  - ➢ ចរិកនៃការស៊ីចំណីរបស់ត្រី វិធីសាស្ត្រសមស្របក្នុងការផ្តល់ចំណីត្រី
  - ➢ ចូលរួមក្នុងសកម្មភាពប្រមូលផលត្រីរបស់កសិករវគ្គទី១ និងធ្វើការវិភាគសេដ្ឋកិច្ច
  - ➢ បានចុះតាមដានគ្រួសារអ្នកចិញ្ចឹមត្រីទាំងចំនួន ៣០គ្រួសារ ជារៀងរាល់សប្តាហ៍
- បានគាំទ្រថវិកា បដិភាគសម្រាប់កសិករថ្មី ដាក់កូនត្រីពូជ ដែលពួកគាត់បានជ្រើសរើសចិញ្ចឹមចំនួន ១៥គ្រួសារ ចំនួន ៨០ដុល្លា ដែលនៅក្នុងនោះកសិករ សម្រេចចិត្តដាក់ពូជត្រីចំនួន ៩ប្រភេទ សរុបចំនួន ២៣,៨២២ក្បាលដូចជា៖
  - ➢ ពូជត្រីឆ្ពិន ចំនួន ១២គ្រួសារ ស្មើនឹងចំនួន ១២,៩៦៣ក្បាល
  - ➢ ពូជត្រីទីឡាព្យ៉ា ចំនួន ៥គ្រួសារ ស្មើនឹងចំនួន ៤,០៦៤ក្បាល
  - ➢ ពូជត្រីប្រាចំនួន ៣គ្រួសារ ស្មើនឹងចំនួន ១,៣៧០ក្បាល
  - ➢ ពូជត្រីក្រាញ់ចំនួន ៣គ្រួសារ ស្មើនឹងចំនួន ២,៩៤៥ក្បាល
  - ➢ ពូជត្រីអណ្តែងចំនួន ៣គ្រួសារ ស្មើនឹងចំនួន ១,១០០ក្បាល
  - ➢ ពូជត្រីកាបសាមញ្ញចំនួន ២គ្រួសារ ស្មើនឹងចំនួន ៧១០ក្បាល
  - ➢ ពូជត្រីរៀលចំនួន ១គ្រួសារ ស្មើនឹងចំនួន ៥០០ក្បាល
  - ➢ ពូជត្រីកាបឥណ្ឌា ចំនួន ១គ្រួសារ ស្មើនឹងចំនួន ១៥០ក្បាល
  - ➢ ពូជត្រីកន្ធរចំនួន ១គ្រួសារ ស្មើនឹងចំនួន ២០ក្បាល
- បានរៀបចំកិច្ចប្រជុំពិភាក្សារវាងកសិករ និងកសិករ ដើម្បីចែករំលែកបទពិសោធន៍ ចំណេះដឹង បញ្ហាប្រឈម និងដំណោះស្រាយចំនួន ៤លើកមានអ្នកចូលរួមចំនួន៣១នាក់ស្រី១២នាក់។
- បានសហការជាមួយនឹងដៃគូ ដើម្បីរៀបចំសិក្ខាសាលបញ្ចប់គម្រោងវគ្គទី១ និង ពិភាក្សាសម្រាប់សកម្មភាពអាទិភាពសម្រាប់វគ្គទី២ ដែលមានអ្នកចូលរួមសរុប៣២នាក់/ស្រី៨នាក់។
- បានសម្ភាសន៍កសិករចំនួន១៣នាក់ស្រី១១នាក់ អំពីគោលបំណងនៃការចិញ្ចឹមត្រី បញ្ហាប្រឈម និងស្វែងរកដំណោះស្រាយ ព្រមទាំងផែនការអនាគត។

## ៤. របាយការណ៍ហិរញ្ញវត្ថុ

អង្គការអ្នកត្រួសត្រាយនៃកម្ពុជា បានកំណត់យក ខែ មករា ដល់ ខែ ធ្នូ ជាឆ្នាំសារពើពន្ធ សម្រាប់ឆ្នាំនីមួយៗ។ ខាងក្រោមនេះគឺជារបាយការណ៍ហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០២២៖

| របាយការណ៍ហិរញ្ញវត្ថុ | ២០២២ |
|---|---|
| **មូលនិធិ** | |
| -មូលនិធិយោងពីឆ្នាំ ២០២១ | ៤៤៩,៧២៧,៥០០ រៀល |
| -មូលនិធិពីម្ចាស់ជំនួយសរុប | ១,០៤០,៦៣៥,៤០០ រៀល |
| **មូលនិធិសរុប** | ១,៤៩០,៣៦៣,៩០០ រៀល |
| **ការចំណាយរបស់គម្រោង** | |
| -អភិវឌ្ឍខ្សែច្រវ៉ាក់តម្លៃត្រី | ២១៩,៥៧៨,២០០ រៀល |
| -គម្រោងវារីវប្បកម្មនៅកម្ពុជា | ៨៩,៤៨៧,៧០០ រៀល |
| -ធនាគារសាប៊ូ | ១,០១០,៣៣៧,៥០០ រៀល |
| -សកម្មភាពប្រតិបត្តិការ និង រដ្ឋបាល | ៤៤,៧០៨,៥០០ រៀល |
| **ការចំណាយសរុប** | ១,៣៦៤,១១១,៩០០ រៀល |
| **សមតុល្យសរុប** | ១២៦,២៥២,000 រៀល |

## ៥. បញ្ហាប្រឈម

- ពិបាកក្នុងការសំបកកេសសម្រាប់ខ្ចប់សាប៊ូ
- ឧបករណ៍សម្រាប់អ៊ុតសាប៊ូ មិនមានក្នុង Stock ធ្វើឲ្យពិបាកនៅពេលឧបករណ៍ខូចពិបាកស្វែងរកទិញភ្លាមឱ្យទាន់ពេល
- ពិបាករកគ្រឿងបន្លាស់ម៉ាស៊ីន ត្រូវចំណាយពេលបញ្ជាទិញពីក្រៅប្រទេស
- មិនទាន់មានរូបមន្តលាយក្លិនជាក់លាក់(ខ្វះបច្ចេកទេស)
- សាប៊ូដែលផលិតហើយមួយចំនួនមិនស្ងួត ដោយសារវត្ថុធាតុដើមមានជាតិប្រេងច្រើន
- មិនសូវមានកសិករចាប់អារម្មណ៍ក្នុងការអនុវត្តគម្រោង (កញ្ចប់ថវិកាបដិភាគតិច)
- ពិបាករកស្រះដែលមានលក្ខណៈស្រះភ្ជាប់ និងវាលស្រែ
- កសិករខ្លះមិនបានកត់ត្រាការចំណាយឱ្យបានត្រឹមត្រូវ
- ស្រះកសិករខ្លះមិនបានប្រមូលផលត្រីដោយរដូវវស្សាចូលមកដល់(ភ្លៀងបន្តបន្ទាប់)
- កូនត្រីដែលទើបដាក់ថ្មីងាប់ច្រើន ដោយសារភ្លៀងខ្លាំងរាល់ថ្ងៃ ធ្វើឲ្យកម្រិតអុកស៊ីសែន និងកម្រិត ប៉េហាស់ចុះទាប
- កសិករខ្លះមិនបានពិនិត្យគុណភាពទឹកមុនពេលដាក់កូនត្រីចូល
- មិនបានរៀបចំហាប៉ា(កន្លែងស្តុកកូនត្រីចូលថ្មី) ឱ្យបានត្រឹមត្រូវមុនពេលដាក់ចូល
- គុណភាពទឹកក្នុងស្រះមួយចំនួនមិនល្អ មានល្បាប់ដីច្រើន ជាបញ្ហារំខានដល់ការលូតលាស់របស់ត្រី
- ស្ថានភាពទឹកជំនន់ហក់ឡើងខ្លាំង និងភ្លៀងជាប្រចាំ

## ៦. ផែនការទិសដៅការងារបន្ត

- ចុះកិច្ចព្រមព្រៀងគម្រោងថ្មី ជាមួយនឹងអង្គការ វើលហ្វីស លើគម្រោង "បង្កើតមណ្ឌលសិក្សាសហគមន៍ដើម្បីធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធអេកូឡូស៊ីត្រី"

- ស្វែងរកទីផ្សារជូនកសិករ និងភ្ជាប់កសិករបណ្តាញទីផ្សារ ទស្សនៈកិច្ចសិក្សា និងស្រាវជ្រាវបន្ត

**<u>គម្រោងទី១៖</u>**

- ធ្វើការស្វែងរកប្រភពវត្ថុធាតុដើមបន្ថែមដើម្បីបង្កើនការផលិតឱ្យតម្រូវការអ្នកប្រើប្រាស់
- ជម្រុញការផលិត និងទំនាក់ទនងទៅអង្គការដៃគូ សហគមន៍ និងតាមសាលារៀនបន្ថែមទៀត។

**<u>គម្រោងទី២៖</u>**

- ជ្រើសរើសកសិករបន្ថែមដើម្បីចូលរួមអនុវត្តគម្រោង
- ផ្តល់វគ្គបណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមត្រី ភ្ជាប់នឹងវាលស្រែជាលក្ខណៈគ្រួសារ
- កែលម្អប្រព័ន្ធស្រះចិញ្ចឹមត្រី វាលស្រែ និងប្រឡាយតភ្ជាប់សម្រាប់កសិករក្នុងគម្រោង

**<u>គម្រោងទី៣៖</u>**

- ផ្តល់វគ្គបណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមត្រី ភ្ជាប់នឹងវាលស្រែជាលក្ខណៈគ្រួសារ
- កែលម្អប្រព័ន្ធស្រះចិញ្ចឹមត្រី វាលស្រែ និងប្រឡាយតភ្ជាប់សម្រាប់កសិករក្នុងគម្រោង
- រៀបចំកិច្ចប្រជុំជាមួយកសិករចាស់ និងថ្មីចំនួន២៣លើកក្នុងតំបន់គោលដៅ
- ជ្រើសរើសកសិករថ្មីចំនួន៧០នាក់(ក្រឡាញ់២៥នាក់, សូទ្រនិគម២៥នាក់,ប្រាសាទបាគង១០នាក់ និងបន្ទាយស្រី១០នាក់។

ថ្ងៃ សុក្រ ៥ រោច ខែ មាឃ ឆ្នាំខាល ចត្វា .ពស.២៥៦៥
ត្រូវនឹងថ្ងៃទី១០ ខែ កុម្ភៈ ឆ្នាំ២០២៣

**នាយិកា**

**អង្គការអ្នកត្រួសត្រាយនៃកម្ពុជា**

Trailblazer Cambodia Organization

**ធេប ម៉ាលីបុត្រ**

# ៧. ឧបសម្ព័ន្ធ














សកម្មភាពផលិតសាប៊ូ និងប្រភេទសាប៊ូដុំ និងសាប៊ូរូប














សកម្មភាពទស្សនកិច្ចសិក្សាសម្រាប់កសិករទៅ កសិដ្ឋានផលិតកូនត្រី និងបន្សាំកូនត្រី និងសកម្មភាពវគ្គបណ្តុះបណ្តាល